ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
អគ្គនាយកដ្ឋានរដ្ឋបាល
នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល
លេខ...០៩៤...........ន.ប.ប.

ថ្ងៃ សុក្រ ១៥កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៨

**សូមគោរពជូន**

- **ឯកឧត្តមអគ្គាធិការ នៃអគ្គាធិការដ្ឋាន**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋាន ប.គ.ព.**
- **ឯកឧត្តម ប្រធានវិទ្យាស្ថានជាតិប.ទ.ប.គ.ព.**
- **ឯកឧត្តម ប្រធាននិយ័តករទូរគមនាគមន៍កម្ពុជា**
- **លោកប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង**
- **លោក លោកស្រី ប្រធានមន្ទីរប.ទ.ខេត្ត**

**កម្មវត្ថុ** : ករណីស្តីពីវគ្គបណ្តុះបណ្តាលនៅប្រទេសឥណ្ឌា សម្រាប់ឆ្នាំសិក្សា ២០១៧-២០១៨ ។

**យោង** : លិខិតលេខ ១៦៨១ កបទ.សអ/អបម ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៨ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជូន **ឯកឧត្តមអគ្គាធិការ ឯកឧត្តមអគ្គនាយក ឯកឧត្តមប្រធានវិទ្យាស្ថាន** និង **លោក លោកស្រីប្រធាន** ជ្រាបថា ភាគីឥណ្ឌាបានជូនព័ត៌មានថា កន្លងមកមានមន្ត្រីរាជការស៊ីវិលកម្ពុជាចំនួនតែ **៩៨រូប** ដែលបានចូលរួមវគ្គបណ្តុះបណ្តាលនៅឥណ្ឌា សម្រាប់ឆ្នាំសិក្សា ២០១៧-២០១៨។

អាស្រ័យហេតុដូចបានគោរពជូនខាងលើ សូម **ឯកឧត្តម** និង **លោក លោកស្រីប្រធាន** មេត្តាជួយផ្សព្វផ្សាយវគ្គបណ្តុះបណ្តាលខាងលើជូនដល់មន្ត្រីក្រោមឱវាទដែលមានចំណាប់អារម្មណ៍ និងលើកទឹកចិត្តដាក់ពាក្យសុំចូលរៀនវគ្គសិក្សាភាសាអង់គ្លេស និងវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងព័ត៌មានវិទ្យា ដោយសារភាគីឥណ្ឌាបានគ្រោងទុកចំនួន១៥០កន្លែង សម្រាប់ឆ្នាំសិក្សា២០១៧-២០១៨។ សូម **ឯកឧត្តម** និង **លោក លោកស្រីប្រធាន** មេត្តាបញ្ជូនព័ត៌មានបេក្ខជនចូលរួមទាំងអស់ និងចម្លងឯកសារដែលបេក្ខជនបានបំពេញបែបបទOnline រួចមកនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល **ឱ្យបាន០៣ខែមុនការចាប់ផ្តើមវគ្គសិក្សានីមួយៗ** ដើម្បីនាយកដ្ឋានធ្វើការរាយការណ៍ជូនថ្នាក់ដឹកនាំ និងឆ្លើយតបទៅស្ថានទូត។ សម្រាប់ព័ត៌មានលម្អិតស្តីពីវគ្គបណ្តុះបណ្តាល និងOnline Registration តាមរយៈគេហទំព័រ https://itecgoi.in ។

សូម **ឯកឧត្តម** និង **លោក លោកស្រីប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

**ប្រធាននាយកដ្ឋាន**

**ជួន ដារ៉ូ**